**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**
លេខ.....០០៧១ ប្រក.....

**ក្រសួងកិច្ចការនារី**

# ប្រកាសរួម
## ស្តីពី
## ក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី

**រដ្ឋមន្ត្រី ក្រសួងព័ត៌មាន**　　**រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៥/០៧ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣១ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ ជា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារី ។

## សម្រេច

**ប្រការ១**.-

គោលបំណងនៃប្រកាសរួមនេះ គឺដើម្បីបង្កើតក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់រាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី រួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងអំពើហិង្សាផ្នែកសេដ្ឋកិច្ច ដើម្បីទប់ស្កាត់ការយកករណីហិង្សាទៅលើស្ត្រី ធ្វើជាព័ត៌មានសម្រាប់កំសាន្តសប្បាយ ឬកំប្លុកកំប្លែង និងដើម្បីកែប្រែឥរិយាបថសង្គម ក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី ស្របតាមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨។

**ប្រការ២**.-

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន មិនត្រូវរាយការណ៍ព័ត៌មានដែលរៀបរាប់លម្អិត បង្ហាញខ្លឹមសារលម្អិតឬរូបភាពលម្អិត អំពីសកម្មភាពហិង្សាពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី ឬអំពើរំលោភសេពសន្ថវៈ ដែលបង្កឱ្យមានភាពតានតឹងក្នុងអារម្មណ៍ ចំពោះអ្នកអាន អ្នកស្តាប់ អ្នកទស្សនា ឬអ្នកពាក់ព័ន្ធនោះទេ។

**ប្រការ៣**.-

អ្នកអានព័ត៌មាន និងអ្នករាយការណ៍ព័ត៌មាន គួររាយការណ៍អំពើហិង្សាលើស្ត្រី តាមរបៀបជាការផ្តល់ព័ត៌មានដើម្បីជាប្រភពឱ្យស្ថាប័នពាក់ព័ន្ធចាត់វិធានការដោះស្រាយ ដើម្បីជាគុណប្រយោជន៍សម្រាប់ការអប់រំ សំដៅកែប្រែឥរិយាបថអវិជ្ជមានរបស់សង្គម និងដើម្បីការជជែកពិភាក្សារបស់សាធារណជនទៅលើប្រធានបទអំពើហិង្សាលើស្ត្រី។

**ប្រការ៤**.-

ការរាយការណ៍ គួរយោងទៅលើមាត្រាច្បាប់ជាក់លាក់ណាមួយដែលជនមុខសញ្ញាបានបំពាន និងបង្ហាញអំពីកម្រិតទោសទណ្ឌតាមមាត្រាច្បាប់នោះ ដើម្បីឱ្យអ្នកអាន អ្នកស្តាប់ អ្នកទស្សនា បានយល់ដឹងពេញលេញអំពីលទ្ធផល និងផលប៉ះពាល់ដែលកើតចេញមកពីការប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងដើម្បីទប់ស្កាត់កុំឱ្យមានអំពើហិង្សានេះកើតឡើងទៀត។

**ប្រការ៥**.-

ការរាយការណ៍ ត្រូវបញ្ចូលព័ត៌មានដែលលើកទឹកចិត្តឱ្យសាធារណជន ចេះអំពីរបៀបជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ឬអង្គការសង្គមស៊ីវិលពាក់ព័ន្ធ នៅពេលអំពើហិង្សាលើស្ត្រីកើតឡើង។ ការរាយការណ៍ មិនត្រូវបង្ហាញអត្តសញ្ញាណរបស់អ្នកផ្តល់ព័ត៌មានអំពីករណីហិង្សានោះទេ។

**ប្រការ៦**.-

ការរាយការណ៍ មិនត្រូវបង្ហាញរូបភាពឬវីដេអូ របស់ជនរងគ្រោះនិងជនមុខសញ្ញានៃអំពើហិង្សា ឬផ្តល់ព័ត៌មានដែលនាំឱ្យអ្នកអាន អ្នកស្តាប់ ឬអ្នកទស្សនា បានដឹងច្បាស់អំពីអត្តសញ្ញាណរបស់ជនរងគ្រោះ និងជនមុខសញ្ញាឡើយ។ ក្នុងករណីចាំបាច់ដែលត្រូវបង្ហាញរូបភាពជនរងគ្រោះឬជនមុខសញ្ញានោះ ការរាយការណ៍ត្រូវដាក់រូបឱ្យព្រាលដើម្បីកុំឱ្យស្គាល់អត្តសញ្ញាណ។

**ប្រការ៧**.-

ការរាយការណ៍ ត្រូវតែគោរពឯកជនភាព សេចក្តីថ្លៃថ្នូរ និងការពារសុវត្ថិភាពរបស់ជនរងគ្រោះ ទោះជារូបភាពវីដេអូ ឬព័ត៌មានទាំងនោះ យកចេញពីប្រភពណាក៏ដោយ ដូចជា ៖

- ចៀសវាងប្រើរូបភាពឬវីដេអូដែលបង្ហាញច្បាស់ៗអំពីទិដ្ឋភាពនៃការស្លាប់ របួស ភាពអាក្រាតកាយ ឬភាពរន្ធត់ ដែលកើតចេញពីអំពើហិង្សាលើស្ត្រី
- មិនត្រូវបង្ហាញពីឈ្មោះ និងទីកន្លែងជាក់លាក់ដែលអំពើហិង្សាលើស្ត្រីបានកើតឡើងនោះទេ
- មិនត្រូវបង្ហាញរូបភាពឬវីដេអូ របស់ជនរងគ្រោះនៃអំពើហិង្សា ឬផ្តល់ព័ត៌មានដែលនាំឱ្យអ្នកអាន អ្នកស្តាប់ អ្នកទស្សនា អាចកំណត់បាននូវអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ ក្នុងនោះរួមមាន ការមិនបង្ហាញឈ្មោះ ឬអាសយដ្ឋានស្នាក់នៅរបស់ជនរងគ្រោះ ឬឈ្មោះសាច់ញាតិរបស់ជនរងគ្រោះជាដើម។ ការបង្ហាញអំពីអាសយដ្ឋាន ត្រូវតែមានលក្ខណៈទូលាយ។ ឧទាហរណ៍ ករណីហិង្សាបានកើតឡើងក្នុងឃុំ "ក" ឬ ស្រុក "ខ" ជាជាងការដាក់អាសយដ្ឋានជាក់លាក់ ឬឈ្មោះភូមិជាក់លាក់។

**ប្រការ៨**.-

ដើម្បីរក្សាភាពថ្លៃថ្នូរ និងកាត់បន្ថយអារម្មណ៍នៃភាពអាម៉ាស់របស់ជនរងគ្រោះ អ្នករាយការណ៍ព័ត៌មាន ត្រូវពិនិត្យអត្ថបទឱ្យបានល្អិតល្អន់។ ក្នុងករណីមានការស្នើសុំពីជនរងគ្រោះ ចង់កែតម្រូវចំណុចណាមួយ គួរផ្តល់ឱកាសឱ្យមានការកែតម្រូវឡើងវិញ។

**ប្រការ៩**.-

ត្រូវមានការប្រុងប្រយ័ត្ន ក្នុងការរាយការណ៍អំពីទិដ្ឋភាពនៅក្នុងពេលសវនាការរបស់តុលាការទាក់ទងនឹងការជំនុំជម្រះបទល្មើសនៃអំពើហិង្សាលើស្ត្រីតាមគ្រប់រូបភាព។

**ប្រការ១០**.-

គួរប្រើប្រាស់ភាសាឱ្យបានសមរម្យ និងសុក្រឹត ដើម្បីរក្សាភាពថ្លៃថ្នូររបស់ជនរងគ្រោះនៅពេលរៀបរាប់អំពីករណីអំពើហិង្សាលើស្ត្រី។ ត្រូវចៀសវាងប្រើប្រាស់ពាក្យដូចជា "ស្រីសាវ៉ា, ខ្ចិលច្រអូស, អាស, សហាយស្មន់, ល្មោភកាម" និងភាសាអសុរោះដែលមិនសមរម្យផ្សេងទៀត នៅពេលដែលរៀបរាប់អំពីអំពើហិង្សាលើស្ត្រី។

**ប្រការ១១**.-

ត្រូវចៀសវាងការធ្វើបុរេនិច្ឆ័យលើការរាយការណ៍ព័ត៌មានពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី ដែលអាចនាំឱ្យសាធារណជនយល់ច្រឡំ និងទទួលព័ត៌មានខុស (ឧទាហរណ៍ ការលើកឡើងពីមូលហេតុដែលនាំឱ្យមានអំពើហិង្សាដូចជា គ្រឿងស្រវឹង កង្វះការយល់ដឹង អវិជ្ជា ភាពក្រីក្រ ឬមូលហេតុបង្កដោយជនរងគ្រោះនោះទេ។ មូលហេតុទាំងនេះគ្រាន់តែជាលេស ដែលជនមុខសញ្ញាអាចគេចចេញពីការទទួលខុសត្រូវតាមផ្លូវច្បាប់ និងអាចជាការដាក់ការស្តីបន្ទោសដល់ជនរងគ្រោះទៅវិញ)។

**ប្រការ១២**.-

មិនត្រូវបន្ទោស ឬដាក់កំហុសទៅលើស្ត្រី ចំពោះរាល់អំពើហិង្សាដែលកើតឡើងលើពួកគេនោះទេ។ ការរាយការណ៍ មិនត្រូវដាក់បញ្ចូលនូវមតិផ្ទាល់ខ្លួន ឬការយល់ឃើញផ្ទាល់ខ្លួន ដូចជាថា របៀបនៃការស្លៀកពាក់ របៀបរស់នៅ វិជ្ជាជីវៈ មុខរបរ ចរិតឫកពារ និន្នាការភេទ ទីកន្លែង ឬពេលវេលានៃការប្រព្រឹត្តអំពើហិង្សាជាហេតុបង្កឱ្យមានអំពើហិង្សានោះទេ។

**ប្រការ១៣**.-

គួរប្រើប្រាស់ស្ថិតិអំពើហិង្សាលើស្ត្រី ដែលមានភាពសុក្រឹត និងជឿជាក់បាន ក្នុងការផ្តល់នូវព័ត៌មានច្បាស់លាស់មួយដល់អ្នកអាន អ្នកស្តាប់ អ្នកទស្សនា អំពីភាពញឹកញាប់ដែលបទល្មើសនេះបានកើតឡើង។ ត្រូវចៀសវាងការវាយតម្លៃជាលក្ខណៈទូទៅណាមួយដោយគ្មានការផ្អែកលើព័ត៌មានពិតជាក់លាក់។ ការរាយការណ៍ព័ត៌មាន គួរបញ្ចូល

ព័ត៌មានអំពីនិន្នាការមួយចំនួនដូចជា ហេតុការណ៍ពិតនៃអំពើរំលោភសេពសន្ថវៈដែលបានកើតឡើងភាគច្រើនបំផុត គឺប្រព្រឹត្តិដោយជនដែលស្គាល់គ្នាជាមួយជនរងគ្រោះ។

**ប្រការ១៤.-**

ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រីតាមប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ ត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវនៃប្រកាសរួមនេះ។

**ប្រការ១៥.-**

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ រួមទាំង អ្នករាយការណ៍ព័ត៌មាន អ្នកអានព័ត៌មាន និពន្ធនាយក ត្រូវអនុវត្តប្រកាសរួមនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២០... ខែកក្កដា.. ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**ខៀវ កាញារីទ្ធ**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ..២០... ខែ កក្កដា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**អ៊ឹង កន្ថាផាវី**

កន្លែងទទួលៈ

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកិច្ចការនារី
- គ្រប់អគ្គនាយកដ្ឋានចំណុះក្រសួងព័ត៌មាន "ដើម្បីជ្រាប"
- មន្ទីរព័ត៌មានរាជធានីខេត្ត
- មន្ទីរកិច្ចការនារីរាជធានីខេត្ត
- សមាគមវិទ្យុ ទូរទស្សន៍កម្ពុជា
- សមាគមសារព័ត៌មាន
- គ្រប់ស្ថានីយវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី
- ដូចប្រការ១៥ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ